## បញ្ហាដែលអាចកើតឡើងដោយចៃដន្យនៅពេលអ្នកផ្ដល់ឈាម

ការផ្ដល់ឈាមពិតជាមានសុវត្ថិភាពជាទីបំផុត ដោយពួកយើងមានវិធីសាស្ត្រក្នុងការកាត់បន្ថយនូវបញ្ហាដែលអាចកើតមានឡើងនៅពេលផ្ដល់ឈាម។ ប៉ុន្តែពេលខ្លះបញ្ហាបន្តិចបន្តួចក៏អាចកើតមានឡើងផងដែរ ក្នុងអំឡុងពេលផ្ដល់ឈាម និងក្រោយពេលផ្ដល់ឈាម ដូចជាការឡើងជាំលើស្បែកបន្តិចបន្តួចបន្ទាប់ពីការផ្ដល់ឈាម។ យ៉ាងណាមិញ ការឡើងជាំនេះនិងបាត់ទៅវិញក្នុងរយៈពេលប៉ុន្មានថ្ងៃបន្ទាប់ពីការផ្ដល់ឈាម ដោយមិនមានអ្វីគួរអោយព្រួយបារម្ភទេ។ យើងអាចកាត់បន្ថយការឡើងជាំនេះបានដោយការសំរាកដៃ ឬ បន្ថយការប្រើប្រាស់ដៃដែលបានផ្ដល់ឈាមនោះក្នុងរយៈពេល ១៥នាទីដំបូងបន្ទាប់ពីការបូមឈាមរួច ឬ បើអាចគួរតែបន្តសំរាកដៃដោយមិនធ្វើការធ្ងន់រយៈពេល១២ម៉ោង។ បើសិនជាដៃរបស់អ្នកមានឡើងជាំរួមផ្សំជាមួយការឈឺចាប់ខ្លាំង អ្នកអាចប្រើប្រាស់ថ្នាំបំបាត់ការឈឺចាប់ដូចជា Paracetamol និងស្អំដៃជាមួយទឹកកកដើម្បីជួយបន្ថយការឈឺចាប់នេះ។ អ្នកអាចទាក់ទងមកមន្ទីរពេទ្យផ្ទាល់តាមរយៈទូរស័ព្ទដើម្បីសុំការពិភាក្សាបន្ថែម។

## ការហូរឈាមនៅកន្លែងចាក់ម្ជុល

ប្រសិនជាមានបញ្ហានេះកើតមានឡើងក្រោយពេលផ្ដល់ឈាម អ្នកគួរគប្បីលើកដៃរបស់អ្នកអោយខ្ពស់ជាងស្មា រួចសង្កត់ត្រង់កន្លែងចាក់ម្ជុលកុំស្លន់ស្លោហើយស្រែកសុំរកជំនួយពីបុគ្គលិកនៅកន្លែងផ្ដល់ឈាម។ អ្នកអាចជៀសវាងការហូរឈាមនេះបានដោយសំរាកដៃដែលបានផ្ដល់ឈាមរយៈពេល១៥នាទី និងប្រើប្រាស់ដៃថ្មមៗនៅពេលលើកដៃញ៉ាំអី ឬពាក់សំលៀកបំពាក់។

## វិលមុខក្រោយពេលផ្ដល់ឈាម

សូមប្រាប់ទៅកាន់បុគ្គលិកយើងភ្លាមៗ ប្រសិនជាអ្នកមានអាការះវិលមុខក្នុងអំឡុងពេលផ្ដល់ឈាម។ ប្រសិនជាអ្នកវិលមុខក្រោយពេលផ្ដល់ឈាមសូមអង្គុយចុះ
រឺ សំរាករយៈពេល ៣០នាទី ឬ រហូតដល់ពេលអ្នកបាត់វិលមុខ នឹង ត្រូវពិសារទឹកអោយបានច្រើន។
ការជក់បារីក្រោម ១ម៉ោងដំបូងក្រោយពេលផ្ដល់ឈាម ត្រូវបានហាមឃាត់ ព្រោះបារីអាចធ្វើអោយអ្នកវិលមុខផងដែរ។

## ការឈឺចាប់

ការចាក់ម្ជុលដើម្បីផ្ដល់ឈាមអាច ប៉ះទៅលើសរសៃប្រសាទ ឬ សរសៃពួរដែលនៅក្រោមស្បែកហើយអាចធ្វើអោយអ្នកមានអារម្មណ៍ឈឺចុកចាប់ប៉ុន្តែករណីនេះអាចកើតមានឡើងដោយកំរ។ សូមប្រាប់យើងភ្លាមៗ ប្រសិនជាអ្នកមានបញ្ហានេះ។

## ញ័រ ឬ ថប់ដើមទ្រូង

វាជាករណីកំរ ករណីញ័រ ឬ ថប់ទ្រូងក្រោយពេលផ្ដល់ឈាមជាពិសេសអ្នកផ្ដល់ឈាមដែលមានវ័យចំណាស់ សូមផ្ដល់ពត៌មានដល់ភ្នាក់ងារយើងប្រសិនជាអ្នកមានបញ្ហានេះក្នុងអំឡុងពេលផ្ដល់ឈាម ឬ ក្រោយពេលផ្ដល់ឈាមក៏ដោយ។ប៉ុន្តែបើអ្នកមានបញ្ហានេះក្រោយពេលចាកចេញពីមន្ទីរពេទ្យហើយអ្នកអាចទំនាក់ទំនងមកយើងវិញរឺក៏អ្នកអាចទៅជួបជាមួយគ្រូពេទ្យដែលនៅជិតផ្ទះដើម្បីពិនិត្យអោយបានត្រឹមត្រូវ។

មន្ទីរពេទ្យអនុស្សាវរីយ៍
ស៊ុនយ៉ាឃីល
Sonja Kill
MEMORIAL HOSPITAL

Managed by
HOPE worldwide

# ការបរិច្ចាគឈាមនៅ

# Sonja Kill Memorial Hospital



## តើអ្នកណាខ្លះអាចផ្តល់ឈាមបាន?

អ្នកដែលអាចផ្តល់ឈាមបានមានដូចជា

អាយុចន្លោះ ១៨ ទៅ ៦០ ឆ្នាំ

ទំងន់លើសពី ៤៥គីឡូក្រាម

អ្នកមានសុខភាពល្អ

អ្នកអាចផ្តល់ឈាមរៀងរាល់ ៣ខែម្តង សំរាប់បុរស និង ៤ខែម្តង សំរាប់ស្ត្រី

ប្រសិនបើអ្នកមានសុខភាពល្អ មិនមានការចាក់សាក់ក្នុងកំឡុងពេល១ឆ្នាំមុន និងមិនបានរស់នៅក្នុងចក្រភពអង់គ្លេសលើសពីរយះពេល ៦ខែឡើងទៅនៅក្នុងកំឡុង ឆ្នាំ ១៩៨០ ដល់ឆ្នាំ ១៩៩៦ នោះទេ សូមមេត្តាអ្នកសំរេចចិត្តអញ្ជើញមកកាន់មន្ទីរពេទ្យយើងខ្ញុំ ដើម្បីធ្វើការបរិច្ចាគឈាមជួយសង្គ្រោះដល់ជីវិតមនុស្ស ។

## មុនពេលអ្នកបរិច្ចាកឈាម

**តើអ្នកមានបានបរិភោគអាហារ ហើយរឺនៅរយះពេល៣ម៉ោងមុននេះ?**

ប្រសិនបើនៅ អ្នកត្រូវបរិភោគអោយបានមុនពេលបរិច្ចាកឈាម។

**តើធម្មតាអ្នកមានសំពាធឈាមទាបឬទេ?**

តើអ្នកមានអារម្មណ៍វិលមុខទេពេលអ្នកក្រោកឈរភ្លាមៗ? ប្រសិនបើមានសូមប្រាប់ពួកខ្ញុំ

**តើអ្នកមានអារម្មណ៍ភ័យខ្លាចទេ ?**បើមានសូមប្រាប់ពួកខ្ញុំអោយដឹង ដើម្បី ពួកខ្ញុំជួយអ្នកមានអារម្មណ៍ធូរស្រាល ឬ ក៏អាចណាត់អោយអ្នកមកវិញនៅពេលក្រោយ។

**តើអ្នកធ្លាប់មានប្រតិកម្មជាមួយសារធាតុសំលាប់មេរោគ ឬ បង់រុំឬទេ?**

សូមប្រាប់ពួកខ្ញុំដើម្បី ពួកខ្ញុំអាចរៀបចំតាមវិធីផ្សេង។

## ការចុះឈ្មោះ

ប្រសិនបើអ្នកសំរេចចិត្តក្នុងការបរិច្ចាកឈាម សូមទំនាក់ទំនងមកខាងយើងខ្ញុំ។

## ការពិនិត្យសុខភាព

នៅពេលសម្ភាសជាលក្ខណៈឯកជនពួកយើងនឹង:

-ធ្វើការត្រួតពិនិត្យសុខភាពរបស់អ្នកដើម្បីរកបញ្ហាដែលអាចប៉ះពាល់ដល់អ្នកទទួលឈាមរបស់អ្នក។

-ធ្វើការត្រួតពិនិត្យដើម្បីប្រាកដថា ការបរិច្ចាកឈាមមិនប៉ះពាល់ដល់សុខភាពរបស់អ្នក

-ធ្វើការពិនិត្យលើសំនួរដែលបានឆ្លើយទាក់ទងពីសុខភាពរបស់អ្នក

-ពិនិត្យអាយុរបស់អ្នកគឺត្រូវលើសពី ១៨ឆ្នាំប្រាកដថាពត៍មានដែលអ្នកបានបំពេញគឺត្រឹមត្រូវ

-មានការយល់ព្រមពីអ្នកដើម្បីយកឈាមទៅពិនិត្យ

-ពិនិត្យគ្រាប់ឈាមក្រហមរបស់អ្នកដោយការជួសចុងម្រាមដៃរបស់អ្នក

## ពេលធ្វើការបរិច្ចាកឈាម

ពួកខ្ញុំនិងរៀបចំអោយអ្នកទៅអង្គុយនៅលើកៅអីបរិច្ចាកឈាម ហើយពិនិត្យមើលពត៍មានរបស់អ្នកម្តងទៀតដើម្បីកំនត់អត្តសញ្ញាណរបស់អ្នកអោយបានត្រឹមត្រូវនឹងតេស្តឈាមរបស់អ្នក។ដើម្បីធ្វើការចាក់ម្ជុលពួកខ្ញុំត្រូវរឹតដៃរបស់អ្នកនឹងខ្សែកៅស៊ូមួយរួចជូតសំអាតស្បែកជាមួយសំឡីអាកុល។

ម្ជុលនោះអាចអោយអ្នកមានអារម្មណ៍ដូចគេក្តិច តែបន្តិចនោះទេ បន្ទាប់ពីនេះ អំឡុងពេលធ្វើការបរិច្ចាកឈាមអ្នកនិងមានអារម្មណ៍ធម្មតាដោយគ្មានការឈឺចាប់នោះទេ ហើយជាទូទៅចំណាយពេលត្រឹមតែ ១០នាទីប៉ុណ្ណោះ។

អំឡុងពេលដំណើរការប្រមូលឈាមអ្នកត្រូវបានលាដៃ និង ក្តាប់ដៃជាមួយកៅស៊ូ។ បើសិនមានអារម្មណ៍ឈឺ ឬ មិនស្រួលសូមប្រាប់ពួកខ្ញុំភ្លាមៗ។

ក្នុងការបរិច្ចាកឈាមនីមួយៗពួកខ្ញុំប្រើថ្លោកឈាមនិងម្ជុលថ្មី។ ម្ជុលនិងថ្លោកឈាម ដែលប្រើហើយមិនត្រូវបានយកមកប្រើប្រាស់ម្តងទៀតទេ។ បន្ទាប់ពីបរិច្ចាកឈាមប្រហែល ៣៥០មីលីលីត្ររួច ម្ជុលត្រូវបានដកចេញវិញ។ គ្រូពេទ្យ និងពឹងអោយអ្នកជួយសង្កត់កន្លែងដែលដកម្ជុលជាមួយនឹងសំឡីអាកុលពីលើ ហើយគ្រូពេទ្យនិងយកបង់រុំកន្លែងដកម្ជុលនោះអោយ។

## អ្នកអាចសំរាកបានហើយឥឡូវនេះក្រោយពីការផ្តល់ឈាម

បន្ទាប់ពីសំរាកនៅលើកៅអីបរិច្ចាកឈាមប្រហែល ៥នាទី អ្នកនឹងទទួលបាន ភេសជ្ជះ ដើម្បីជួយបំពេញឈាមដែលអ្នកបានបរិច្ចាក ដូចនេះសូមពិសារភេសជ្ជះ និងអាហារដែលយើងផ្តល់អោយអ្នក។អ្នកត្រូវរងចាំ ១០ទៅ១៥នាទីទៀត ដើម្បីអោយខ្លួនអ្នកមានតុល្យភាពត្រឹមត្រូវសិន មុនពេលចាកចេញ៕

## ឥឡូវអ្នកអាចត្រលប់ទៅវិញបានហើយ

ក្រុមការងារយើងខ្ញុំនឹងផ្តល់កាតដែលមានលេខកូដ និង ក្រុមឈាមរបស់អ្នកអោយទៅអ្នក បន្ទាប់ពីធ្វើការបរិច្ចាកហើយ។

បន្ទាប់ពី ៤៨ម៉ោង ក្រោយមកបើអ្នកមានអាការះ ដូចជា រាគ ឬ មិនស្រួលក្នុងខ្លួន ឬ អ្នកទើបតែនឹកឃើញពីជំងឺដែលអ្នកមានជាប្រចាំហើយអ្នកភ្លេចប្រាប់មកយើងខ្ញុំ។

សូមទំនាក់ទំនងតាមលេខទូរស័ព្ទខាងក្រោម:

អ្នកផ្តល់ពត៍មាន: ០១២ ៣៤៥ ៦៧៨

ផ្នែកបរិច្ចាកឈាម: ០១០ ២៩៣ ៩៧៥

ផ្នែកសេវាសង្គ្រោះបន្ទាន់: ០១២ ៣៤៥ ៦៨០